# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ មិថុនា ឆ្នាំ ២០១៤
## និងទិសដៅការងារ ខែ កក្កដា ឆ្នាំ ២០១៤

( ពីថ្ងៃទី២៦/០៥/២០១៤ ដល់ ២៥/០៦/២០១៤ )

ដោយផ្អែកលើផែនការសកម្មភាពអនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ត្រីមាសទី២ ឆ្នាំ២០១៤ និង ទិសដៅការងារ ដែលបានដាក់ចេញកាលពីខែឧសភា ឆ្នាំ២០១៤ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្ត " គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋទទួលបានលទ្ធផលដូចខាងក្រោម ។

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាល និង កងរាជអាវុធហត្ថ រាជធានី-ខេត្ត ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរ និងប្រើប្រាស់គ្រឿងញៀន បានកើតមាននៅ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ឆ្នាំង, កំពង់ចាម, សៀមរាប, ស្ទឹងត្រែង, រតនគិរី, កំពត, បាត់ដំបង, បន្ទាយមានជ័យ, ពោធិ៍សាត់, កំពង់ធំ, ក្រចេះ, មណ្ឌលគិរី និង ខេត្តឧត្តរមានជ័យ ។ ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបបាន ក្នុងខែមិថុនានេះ កត់សំគាល់ឃើញមាន ២ ករណីធំៗ ដែលបង្ក្រាបដោយ ៖

- មន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ១ ករណី ព្រមទាំងដកហូតមេតំហ្វេតាមីនក្រាមម្សៅ (ICE) ចំនួន ២,៤៣៨ គ.ក្រ ។
- កងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ១ ករណី ព្រមទាំងដកហូតមេតំហ្វេតាមីន WY ជាង ១,៥៩៥ គ.ក្រ ។

## II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. អំពីការងារដឹកនាំ

***- ការដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ***

ខែមិថុនានេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្ញើសារលិខិតគាំទ្រនិងអំពាវនាវដល់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី សហគមន៍និងពលរដ្ឋគ្រប់រូបត្រូវចូលរួមអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព[1]" ដើម្បីចាត់វិធានការការពារកុមារគ្រប់រូបពីអំពើហឹង្សាតាមគ្រប់រូបភាព នៅក្នុងឱកាសខួបលើកទី៦៥ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៤ និងធ្វើការណែនាំ អំពាវនាវបន្ថែមចំនួន ៦ ចំណុចពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន នៅក្នុងឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ ក្រោមប្រធានបទ "រួមគ្នាបង្ការ និងដោះស្រាយបញ្ហាគ្រឿងញៀន" ។

- ***ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន***

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ ដឹកនាំបញ្ជា និងចូលរួមផ្ទាល់លើការងារជាគោលសំខាន់ៗ ជាអាទិ៍ :

- ចូលរួមប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងបានណែនាំឲ្យគ្រប់ខេត្តនៅទូទាំងប្រទេសចូលរួមប្រារព្ធទិវានេះ ។
- ណែនាំដល់អគ្គលេខាធិការដ្ឋាន ឲ្យ ៖
  - ✓ ផ្សព្វផ្សាយលទ្ធផលការសិក្សាស្តីពីការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀនថ្នាក់ជាតិ ការអង្កេតឥរិយាបថប្រឈមចំពោះមេរោគអេដស៍ និងប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ។
  - ✓ រៀបចំបែបបទប្រគល់សារជាតុគីមីផ្សំ ចំនួន ១៤ មុខ មានទម្ងន់ ១៨ តោន និង៩០០ គ.ក្រ ដែលសមត្ថកិច្ចបង្ក្រាប និងចាប់យកកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ក្នុងករណីប៉ុនប៉ងលួចលាក់ផលិតគ្រឿងញៀនខុសច្បាប់ ទៅឲ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។
  - ✓ ជំរុញក្រសួងទេសចរណ៍ អនុវត្តអនុក្រឹត្យ លេខ ១៩១ អ.ន.ក្រ/បក ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងជំរុញអនុវត្តការអប់រំបង្ការ ទប់ស្កាត់និងបង្ក្រាបឲ្យបានសកម្មថែមទៀតនូវផលិតផល ស៊ីហ្សា និង បារីអេឡិចត្រូនិច ។
  - ✓ ជំរុញក្រសួងសុខាភិបាលក្នុងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមមន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព ក្នុងរាជធានីភ្នំពេញ ។
  - ✓ បើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជំនាញ ដល់មន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិចាប់ពីថ្នាក់ខេត្ត រហូតដល់ ថ្នាក់ប៉ុស្តិ៍រដ្ឋបាលមូលដ្ឋាន ។
  - ✓ បើកវគ្គបណ្តុះបណ្តាលជនបង្គោល នៃកងយោធពលខេមរភូមិន្ទ និងនៅតាមបណ្តាភូមិភាគ ។
  - ✓ ជំរុញការរៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

---

[1] នៅក្នុងលក្ខណៈសម្បត្តិទី២ នៃគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព បានចែងថា គ្មានការផលិត ការចែកចាយ និងប្រើប្រាស់ គ្រឿងញៀនខុសច្បាប់

- ✓ សហការជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីកែសម្រួលខ្លឹមសារឯកសារបណ្ដុះបណ្ដាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ស្ដីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

## ២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ២.១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

ផ្ដើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្ដម ឧបនាយរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែឧសភា ឆ្នាំ២០១៤ កន្លងទៅ ក្រសួង-ស្ថាប័នជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ សប្ដាហ៍ ខែ, ការអប់រំតាមសហគមន៍ ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានក្នុងឧបសម្ព័ន្ធទី១** ។ **ក្នុងនោះ** លទ្ធផលដែលបានអនុវត្តដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមមាន :

- បន្តផ្ដល់ការគាំទ្រ និងតាមដានការអនុវត្តសកម្មភាពអប់រំរបស់ក្លឹបយុវជន ការចុះប្រមូលព័ត៌មាន/ទិន្នន័យ និងសិក្ខាសាលាស្ដីពី " ការលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការអប់រំបង្ការគ្រឿងញៀន និងគ្រឿងស្រវឹង"តាមវិទ្យាល័យ ឃុំ/សង្កាត់ នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប និង ខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ២០១៤ ដែលអនុវត្តដោយសមាគមយុវជនខ្មែរ ។
- ផ្ដល់កិច្ចសម្ភាសន៍ដល់ស្ថានីយវិទ្យុ-ទូរទស្សន៍ជាតិ តាមរយៈកម្មវិធី អរុណសួស្ដីកម្ពុជា ក្រោមប្រធានបទស្ដីពីបញ្ហាគ្រឿងញៀននៅកម្ពុជា ។
- បន្តអនុវត្តកម្មវិធីសម្រាប់ប្រិយមិត្តអ្នកអាន **សារ** អប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមគេហទំព័រ របស់ អ.ជ.ប.គ.ញ **ប្រចាំខែមិថុនា** មានប្រិយមិត្តអ្នកអានចំនួន **២២.៩៦៧** ដង ។
- សហការជាមួយក្រុមហ៊ុន មូសាឈី អេដវឺថាយស៊ីង ខូ.អិល.ធី.ឌី ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅរាជធានីភ្នំពេញ ។
- បន្តកិច្ចសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកោះកុង ដើម្បីរៀបចំកម្មវិធីប្រឡងប្រជែងគូរគំនូរអប់រំពីបញ្ហាគ្រឿងញៀន ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅតាមសហ-គមន៍ ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន **៦** គឺ ខេត្តព្រះសីហនុ, កណ្ដាល, កំពង់ចាម, ក្រចេះ, បាត់ដំបង, ស្វាយរៀង នៅក្នុងខែមិថុនា ឆ្នាំ២០១៤ នេះ មានមហាជនចូលរួមប្រមាណ **៣៤.២០០** លើ **១១៦.៣០៧** នាក់ [(2)] នៃខែឧសភា ឆ្នាំ២០១៤ ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១ ។

### ២.២. ការព្យាបាល ស្ដារនីតិសម្បទា ផ្ដល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

- ***កម្មវិធីកាត់បន្ថយគ្រោះថ្នាក់***

[2] សកម្មភាពផ្សព្វផ្សាយអប់រំ មានការថយចុះដោយសារដូរវិស្សាកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុននានា ត្រូវផ្អាកដំណើរការបណ្ដោះអាសន្ន

- ***ការងារក្នុងប្រទេស***

✓ បានរៀបចំពិធីផ្សព្វផ្សាយលទ្ធផលការសិក្សាស្ដីពី ការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀនថ្នាក់ជាតិ ការអង្កេតលើឥរិយាបថប្រឈមចំពោះមេរោគអេដស៍ និងប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន នៅកម្ពុជា (នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ អ្នកពាក់ព័ន្ធចូលរួមសរុប **៧៦** នាក់) ។

✓ បានចូលរួមក្នុងកិច្ចប្រជុំអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាលើប្រធានបទស្ដីពី គោលនយោបាយគ្រឿងស្រវឹង នៅថ្ងៃទី៣០/៥/២០១៤ តាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ។

✓ បានធ្វើបទបង្ហាញស្ដីពីបញ្ហាគ្រឿងញៀន និងការឆ្លងរីករាលដាលមេរោគអេដស៍ / ជំងឺអេដស៍ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ តាមការស្នើសុំរបស់គណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ នៅខេត្តព្រះវិហារ ៥០ នាក់ , ខេត្តរតនគិរី ៦៦ នាក់ , ខេត្តឧត្តរមានជ័យ ៧៦ នាក់ (សរុប **១៩២** នាក់) ។

- ***ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន***

- ***ការងារក្នុងប្រទេស***

✓ បានចូលរួមកិច្ចប្រជុំ ពិភាក្សាជាមួយសាលារាជធានីភ្នំពេញនិងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញកិច្ចដំណើរការផ្ដល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅរាជធានីភ្នំពេញ ថ្ងៃទី០៩/៦/២០១៤ ។

✓ រៀបចំព្រាងរបាយការណ៍ស្ដីពីការព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ។

- ***ការងារក្រៅប្រទេស***

✓ បានចូលរួមសិក្ខាសាលាអាស៊ាន ឆ្នាំ២០១៤ ស្ដីពីការព្យាបាលអ្នកញៀនគ្រឿងញៀន ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣/៦/២០១៤ នៅប្រទេសថៃ (អ្នកចូលរួម ០៣ រូប / អគ្គលេខាធិការដ្ឋាន ០១ រូប , ក្រសួងសុខាភិបាល ០១ រូប , ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០១ រូប) ។

## ***២.៣. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ក្នុងខែមិថុនានេះ មន្ត្រីអនុវត្តន៍ច្បាប់បានបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

- បទល្មើសគ្រឿងញៀន ដែលបង្ក្រាបបានសរុប ***៩៩ ករណី*** លើ ៥៨ ករណី នៃខែឧសភា ឆ្នាំ២០១៤
- ជនសង្ស័យ ដែលបានឃាត់ខ្លួន សរុប ***២៥៤*** នាក់ លើ ១២០ នាក់ នៃខែឧសភា ឆ្នា២០១៤

  ក្នុងចំនួនបទល្មើសគ្រឿងញៀនទាំង ***៩៩ ករណី*** និង ជនសង្ស័យទាំង ***២៥៤ នាក់*** ខាងលើគឺ :

  ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយកងនគរបាល ***៧៤ ករណី***, ជនសង្ស័យ ***១៨៦ នាក់*** (ស្រី ៣១ នាក់)

  ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយកងរាជអាវុធហត្ថ ***២៥ ករណី***, ជនសង្ស័យ ***៦៨ នាក់*** (ស្រី *១២* នាក់)

- ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលបានឃាត់ខ្លួនទាំង ២៥៤ នាក់ ខាងលើ មាន ៤ សញ្ជាតិ គឺ ខ្មែរ ២៤៧ នាក់ (ស្រី ៤៣ នាក់), វៀតណាម ៥ នាក់ (ប្រុស), សឹង្ហបុរី ០១ នាក់

(ប្រុស), ម៉ាឡេស៊ី ០១ នាក់ (ប្រុស), ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក រួមមាន** មេតំហ្វេតាមីន WY ១.៧៦០,៥៨ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ២.៧៤៥,៤៤ ក្រាម, ហេរ៉ូអ៊ីន ២៨០,៣៩ ក្រាម, កេតាមីន ៩១,៥៣ ក្រាម, កញ្ឆាក្រៀម ៥៦០,៣៤ ក្រាម, សារធាតុសង្ស័យគ្រឿងញៀន ១.៥៧៨,៩៧ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** បានចាប់យករួមមាន ម៉ូតូ ២៩ គ្រឿង, រថយន្ត ៤ គ្រឿង, ប្រាក់កម្ពុជា ៦.៩៦៨.១០០ រៀល, ប្រាក់ថៃ ៤៨០ បាត, ប្រាក់អាមេរិក ១.៣០០ ដុល្លារ **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២ ។**

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៦ ដីកា = មនុស្ស ៥ នាក់ (ស្រី១នាក់) ជនជាតិខ្មែរ ។

ក្រៅពីការងារខាងលើ មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាក សង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុង ខែមិថុនា ឆ្នាំ២០១៤ នេះ សរុបចំនួន ៧៤ ករណី = ៩១ សំណាក ។ ក្នុងនោះ **:**

- ✓ សំណាកវិជ្ជមានសារធាតុញៀន មាន ៦៨ ករណី = ៨៥ សំណាក គឺ :
  មេតំហ្វេតាមីន ICE ៥៨ សំណាក = ៦៣,៧៣%, មេតំហ្វេតាមីន WY ២១ សំណាក = ២៣,០៧%
  MDMA ០២ សំណាក = ២,១៩ %, កេតាមីន ០១ សំណាក = ១,០៩ %
  នីមេតាហ្សេប៉ាម = ០១ សំណាក = ១,០៩ %, អេហ្វេឌ្រីន ០២ សំណាក = ២,១៩ %
- ✓ សំណាកអវិជ្ជមានសារធាតុញៀន ០៦ ករណី = ០៦ សំណាក

## *២.៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងសុខា-ភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុង ខែមិថុនាឆ្នាំ២០១៤ នេះ មានដូចតទៅ ៖

- សារធាតុគីមីចម្រុះ សរុបចំនួន ***៨៥៦.០៣៨*** គ.ក្រ ***៥០០*** ក្រាម ក្នុងនោះ
  - ✓ សារធាតុគីមី ដែលចេញអាជ្ញាបត្រដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ៦៦០.០០០ គ.ក្រ (ពាក់ព័ន្ធនឹងតារាងទីIV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)
  - ✓ សារធាតុគីមី ដែលចេញអាជ្ញាបត្រដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ១៩៦.០០០ គ.ក្រ (ពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)
  - ✓ សារធាតុគីមី ដែលចេញអាជ្ញាបត្រដោយក្រសួងសុខាភិបាល មាន ៣៨ គ.ក្រ ៥០០ ក្រាម (ពាក់ព័ន្ធនឹង តារាង III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ២០ គ.ក្រ , តារាង II នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន មាន ១៨ គ.ក្រ ៥០០ ក្រាម)
- វត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលនាំចូលដោយក្រសួងសុខាភិបាល មាន ៥ គ.ក្រ ៥៥៣ ក្រាម ១៦៨ មិល្លីក្រាម ៨០០ មីក្រូក្រាម (ពាក់ព័ន្ធនឹងតារាង II នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ៣ ក្រាម ១៦៨ ក្រាម ៨០០ មីក្រូក្រាម , ពាក់ព័ន្ធនឹងតារាង III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ៥ គ.ក្រ ៥៥០ ក្រាម)

ជាមួយនេះ អគ្គលេខាធិការដ្ឋាន បានរៀបចំបែបបទប្រគល់ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម នូវសារធាតុគីមីផ្សំ ទម្ងន់ ១៨ តោន និង ៩០០ គីឡូក្រាម ដែលសមត្ថកិច្ចបង្ក្រាបនិងចាប់យកកាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១២ ក្នុងករណីប៉ុនប៉ងលួចលាក់ផលិតគ្រឿងញៀន ។

## ***២.៤. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់***

### ***ការងារក្នុងប្រទេស***

- បានចាត់គ្រូឧទ្ទេសនាមចំនួន ០៤ រូប ចូលរួមផ្តល់បទឧទ្ទេសនាម ក្នុងវគ្គបណ្តុះបណ្តាលជនបង្គោល នៃកងយោធពលខេមរភូមិន្ទ ចំនួន ***៧៥*** រូប (នៅក្រសួងការពារជាតិ, ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤) ។
- បានរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់គម្រោង PATROL របស់អង្គការ UNODC ដើម្បីពិភាក្សាអំពីការរៀបចំផែនការសកម្មភាពដែលត្រូវអនុវត្តបន្ត និងរៀបចំពិធីប្រគល់-ទទួល សម្ភារៈសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន ០៧ មុខ ជូនដល់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, អង្គភាពសម្របសម្រួលព័ត៌មានច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង ខេត្តសៀមរាប, ការិយាល័យ BLO កំពង់ស្រឡៅ (ខេត្តព្រះវិហារ), ការិយាល័យ BLO កោះឈើទាលធំ និង ត្រពាំងគ្រាល (ខេត្តស្ទឹងត្រែង) នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ ។
- បានសហការជាមួយអង្គការ UNODC ចុះវាយតម្លៃការអនុវត្តគម្រោង PATROL នៅការិយាល័យទំនាក់ទំនងព្រំដែនច្រកទ្វារអន្តរជាតិ ព្រំ (ប៉ៃលិន), ដូង (បាត់ដំបង) និង បាវិត (ស្វាយរៀង) ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ។
- បានចាត់បញ្ជូនមន្ត្រី អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០១ រូប ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីការរៀបចំសមាគម Responsible Care កម្ពុជា ដែលរៀបចំដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីផ្តល់ការគាំទ្រដល់វិស័យឯកជន លើការជំរុញយកចិត្តទុកដាក់ដល់បញ្ហាសុវត្ថិ-ភាពឧស្សាហកម្ម សុខភាពសាធារណៈ បរិស្ថាន និងការអភិវឌ្ឍបៃតងក្នុងកិច្ចដំណើរការធុរកិច្ច (ធ្វើនៅសណ្ឋាគារសាន់វ៉េ, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤) ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ០១ រូប ទៅចូលរួមធ្វើបទបង្ហាញស្តីពី ការអនុវត្តគម្រោង PATROL នៅកម្ពុជា ក្នុងសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ស្តីពី ការអង្កេត និងត្រួតពិនិត្យសារធាតុបំផ្លាញស្រទាប់អូហ្សូន (ខេត្តកំពង់ចាម, ថ្ងៃទី២៤-២៥ ខែមិថុនា ឆ្នាំ ២០១៤) អ្នកចូលរួម ***៤៥*** នាក់ ។
- បានចុះត្រួតពិនិត្យទីតាំង សម្ភារៈបច្ចេកទេសសម្រាប់សិក្សាតាមប្រព័ន្ធកុំព្យូទ័រ (CBT) និងប្រមូលរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-វៀតណាម នៅការិយាល័យទំនាក់ទំនងព្រំដែនត្រពាំងផ្លុង ខេត្តកំពង់ចាម (២៦/៥/២០១៤), នៅការិយាល័យទំនាក់ទំនងព្រំដែនត្រពាំងគ្រៀល និង អូរស្វាយ ខេត្តស្ទឹងត្រែង (២៨/៥/២០១៤), នៅការិយាល័យទំនាក់ទំនងព្រំដែនកំពង់ស្រឡៅ ១ (៣០/៥/២០១៤) ។

### ***ការងារក្រៅប្រទេស***

- បានចាត់មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចំនួន ៤ រូប និងមន្ត្រីអនុវត្តន៍ច្បាប់ខេត្ត កោះកុង ប៉ៃលិន បាត់ដំបង ពោធិ៍សាត់ បន្ទាយមានជ័យ ២៣ រូប (សរុប ២៧ រូប) ទៅទទួលវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន រវាងកម្ពុជា-ថៃ (នៅខេត្តណាខនណាយុគ ប្រទេសថៃ ១៩-២៣/៥/២០១៤) ។

### ២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជិតខាង

- បានសម្របសម្រួលជាមួយ ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រថៃ ដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលាអាស៊ាន ឆ្នាំ២០១៤ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន ។
- សម្របសម្រួលជាមួយភាគីថៃ ដើម្បីបញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ទៅទទួលវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន រវាងកម្ពុជា-ថៃ ។

### ២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ

- អគ្គលេខាធិការ បានដឹកនាំប្រតិភូទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់ស្តីពីគ្រឿងញៀន នៃបណ្តាប្រទេសសមាជិកហត្ថលេខី ក្នុងមហាអនុតំបន់ទន្លេមេគង្គ កាលពីថ្ងៃទី២៦-៣១ ខែឧសភា ឆ្នាំ២០១៤ នៅសាធារណរដ្ឋប្រជាមានិតចិន ។
- ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ០១ រូប ទៅចូលរួមសិក្ខាសាលាតំបន់ស្តីពីកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិចត្រូនិច នៅទីក្រុងបាងកក ប្រទេសថៃ ពីថ្ងៃទី២៦-២៧/៦/២០១៤ ។

### ២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹង និងពង្រីកលទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យឲ្យមានប្រសិទ្ធភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- បន្តការរៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ចូលជាសមាជិក នៃគណៈកម្មាធិការជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** ស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ CTN និង CNC ស្តីពីសកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ (៣០/៧/២០១៤) ។

**១.២.** បន្តកិច្ចសហការជាមួយក្រុមហ៊ុន Musashi Advertising Co., LTD ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅរាជធានីភ្នំពេញ តាមរយៈការបញ្ចាំងរូបភាព និងភាពយន្តខ្លី នៅលើរថយន្តចល័ត ។

**១.៣.** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យ

ឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន និងការបង្ការទប់ស្កាត់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផល ស៊ីហ្សា និង បារីអេឡិចត្រូនិច នៅតាមរាជធានី-ខេត្ត ទូទាំងប្រទេស ។

**១.៤.** សហការជាមួយក្រសួងទេសចរណ៍ដើម្បីអនុវត្តអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ។

**១.៥.** បន្តការរៀបចំកម្មវិធីប្រឡងប្រណាំងការគូរគំនូរក្រោមប្រធានបទ យើងរួបរួមគ្នាប្រឆាំងគ្រឿងញៀន ។

**១.៦.** បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករតន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ។

**១.៧.** រៀបចំឯកសារសម្រាប់ការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

**១.៨.** បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និងនៅតាមសហគមន៍ ។

**១.៩.** ត្រៀមចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីកម្មវិធី Global SMART របស់អង្គការ UNODC នៅទីក្រុងយ៉ាំងហ្គូន ប្រទេសមីយ៉ាន់ម៉ា ។

## ២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

***២.១.*** បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការបង្កើតសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន (CBTx) និងជំរុញការងារនេះនៅតាមបណ្តាខេត្តគោលដៅ ។

***២.២.*** បន្តការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីបង្កើនការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយឱសថ មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

***២.៣.*** រៀបចំកែសម្រួលសមាសភាពគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ ។

***២.៤.*** បន្តសហការជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការកែសម្រួលឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ស្តីពី យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

## ៣. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់

***៣.១.*** រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន តាមប្រព័ន្ធកុំព្យូទ័រ (CBT) ដល់មន្ត្រីអនុវត្តន៍ច្បាប់នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ចំនួន ១២ រូប ពីថ្ងៃទី០១-០៤/៧/២០១៤ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ។

***៣.២.*** រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់នានា នៅតាមខ្សែបន្ទាត់ព្រំដែន និងមន្ត្រីនៃកងយោធពលខេមរភូមិន្ទ តាមបណ្តាយោធភូមិភាគ ។

***៣.៣.*** បន្តការរៀបចំបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ តាមប្រព័ន្ធកុំព្យូទ័រ (CBT) ។

**៣.៤.** ត្រៀមរៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់ តាមច្រកអាកាសយានដ្ឋានអន្តរជាតិ នៃបណ្តាប្រទេសអាស៊ាន ។

## ***៤. ការត្រួតពិនិត្យសារជាតុគីមីផ្សំ***

**៤.១.** បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ស្លាកសញ្ញាសារជាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

**៤.២.** សិក្សាស្រាវជ្រាវនិងប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុថ្មី ដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ***៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយបណ្តាប្រទេសជាប់ព្រំដែន***

**៥.១.** ជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ / កម្ពុជា-វៀតណាម / កម្ពុជា-ឡាវ ។

**៥.២.** រៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅប្រទេសវៀតណាម និង ឡាវ ។

**៥.៣.** ត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-វៀតណាម លើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀនតាមតំបន់ព្រំដែន (BLO) នៅថ្ងៃទី១៤-១៧ ខែកក្កដា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ។

**៥.៤.** ត្រៀមបញ្ជូនមន្ត្រីការិយាល័យ BLO (០១ រូប) ទៅផ្តល់បទឧទ្ទេសនាមនៅខេត្តសុរិន ប្រទេសថៃ ស្តីពីសភាពការណ៍គ្រឿងញៀន នៅតាមបណ្តោយព្រំដែន ខេត្តព្រះវិហារ និង ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ ។

**៥.៥.** រៀបចំវគ្គបណ្តុះបណ្តាលបមន្ត្រីអនុវត្តន៍ច្បាប់ប្រឆាំងបទល្មើសគ្រឿងញៀន នៃខេត្តព្រះវិហារ ចំនួន ៥០ នាក់ នាថ្ងៃទី២៥-៦/៧/២០១៤ និង មន្ត្រីអនុវត្តន៍ច្បាប់ នៃខេត្តស្ទឹងត្រែង ចំនួន ៥០ នាក់ នាថ្ងៃទី២៨-២៩/៧/២០១៤ ។

## ***៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ***

៦.១. ចាត់បញ្ជូនប្រតិភូរបស់អគ្គលេខាធិការដ្ឋាន ០៤ រូប និងសម្របសម្រួលជូនក្រសួងសុខាភិបាល ០១ រូប, អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ០១ រូប ទៅចូលរួមក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីគ្រឿងញៀន (ASOD) លើកទី៣៥, និង ASOD+ចិន, ASOD+ជប៉ុន, ASOD+កូរ៉េ, ASOD+ឥណ្ឌា នៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន នាថ្ងៃទី០១-០៤ ខែកក្កដា ឆ្នាំ២០១៤ ។

៦.២. ចាត់បញ្ជូនប្រតិភូរបស់អគ្គលេខាធិការដ្ឋាន ០៥ រូប និងសម្របសម្រួលជូនស្ថាប័នពាក់ព័ន្ធ ចំនួន ១០ រូប (សរុប ១៥ រូប) ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសារជាតុគីមីផ្សំ នៅទីក្រុងគុនមិញ សាធារណរដ្ឋប្រជាមានិតចិន នាថ្ងៃទី០១-១៥ ខែកក្កដា ឆ្នាំ២០១៤ ។

៦.៣. ចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ០១, មន្ត្រីធនាគារជាតិ នៃកម្ពុជា ០១ រូប និងមន្ត្រីមន្ទីរប្រឆាំងគ្រឿងញៀន ០១ រូប ទៅទទួលការបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតហិរញ្ញវត្ថុ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន នាថ្ងៃទី០៧-១១ ខែកក្កដា ឆ្នាំ២០១៤ ។

៦.៤. ត្រៀមចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ ១ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន នៅប្រទេសជប៉ុន ។

៦.៥. ចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន១ រូប ទៅបំពេញការងារនៅលេខាធិការដ្ឋាន នៃមជ្ឈមណ្ឌលព័ត៌មាននិងសហប្រតិបត្តិការសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ។

៦.៦. ត្រៀមសហការជាមួយអតីតអ្នកជំនាញការវិភាគគ្រឿងញៀនស្ម័គ្រចិត្តជប៉ុន ដែលអញ្ជើញមកបណ្តុះបណ្តាលបច្ចេកទេសវិភាគគ្រឿងញៀន ដល់មន្ត្រីបច្ចេកទេសនៅមន្ទីរពិសោធន៍គ្រឿងញៀន ។

៦.៧. រៀបចំពិធីទទួលសម្ភារៈសម្រាប់កម្មវិធីបណ្តុះបណ្តាលចល័តស្តីពីគ្រឿងញៀន និងសម្ភារៈសម្រាប់ការិយាល័យ BLO ជ្រៃធំ, ចាំយាម, ព្រំ, ដូង, ប៉ោយប៉ែត ក្រោមជំនួយរបស់គម្រោង PATROL នៃអង្គការ UNODC ។

**៦.១.** ***ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿង ញៀន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ***

**- ថ្នាក់ជាតិ ៖**

៧.១. រៀបចំវគ្គបណ្តុះបណ្តាលអំពីអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៅតាមក្រសួង-ស្ថាប័ន ដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.២. ត្រៀមរៀបចំកិច្ចប្រជុំ គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជាឡាវ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ នៅខេត្តរតនគិរី ។

៧.៣. បន្តរៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**- ថ្នាក់ក្រោមជាតិ ៖**

៧.៤. រៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់ មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ នៅតាមរាជធានី-ខេត្ត ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣
"ដើម្បីជូនជ្រាប"
- ក្រសួង សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋាន សរុប ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
- ឯកសារ